# កិច្ចការដ៏បរិសុទ្ធនៃសុខុមាលភាព

ប៊ីស្សព អេក ដេវីឌ បើរតុន
ប៊ីស្សពជាអធិបតី

*កិច្ចការនៃការមើលថែចំពោះគ្នាទៅវិញទៅមក និងការមាន « ចិត្តសន្ដោសចំពោះអ្នកទ័លក្រ » គឺជាកិច្ចការដ៏បរិសុទ្ធ ដែលព្រះវរបិតាបញ្ជា ។*

ក្នុងឆ្នាំ 1897 ដេវីឌ អូ មិកឃេ វ័យក្មេង បានឈរនៅមាត់ទ្វារ ដោយមានខិត្តប័ណ្ណក្នុងដៃរបស់គាត់ ។ ពេលជាអ្នកផ្សព្វផ្សាយសាសនាម្នាក់ ក្នុងទីក្រុង ស្ទើលឡីង ប្រទេសប្រទេសស្កុតឡែន គាត់បានធ្វើដូច្នេះជាច្រើនដងពីមុនមក ។ ប៉ុន្តែនៅថ្ងៃនោះ ស្ត្រីដ៏ស្លេកស្លាំងម្នាក់បានបើកទ្វារ ហើយឈរនៅចំពោះមុខគាត់ ។ គាត់ស្លៀកពាក់ចាស់ៗ ហើយមានថ្ពាល់ផត និងសក់រញ៉េរញ៉ៃ ។

គាត់បានយកខិត្តប័ណ្ណដែលអែលឌើរ មិកឃេ បានជូនគាត់ ហើយបាននិយាយពាក្យមួយឃ្លាដែល អែលឌើរ មិកឃេ នឹងមិនដែលភ្លេចឡើយ ៖ « តើខិត្តប័ណ្ណនេះនឹងទិញនំប៉័ងសម្រាប់ខ្ញុំបានទេ ? »

ការណ៍នេះបានដក់ជាប់ជានិច្ចក្នុងចិត្តអ្នកផ្សព្វផ្សាយសាសនាវ័យក្មេង ។ ក្រោយមក គាត់បានសរសេរថា « តាំងពីគ្រានោះមក ខ្ញុំយល់ដឹងយ៉ាងជ្រាលជ្រៅថាសាសនាចក្រនៃព្រះគ្រីស្ទ គួរតែ និងត្រូវចាប់អារម្មណ៍ចំពោះសេចក្ដីសង្គ្រោះខាងសាច់ឈាមរបស់មនុស្ស ។ ខ្ញុំបានដើរចេញពីទ្វារ ដោយមានអារម្មណ៍ថា [ ស្ត្រី ] នោះ...ជាមួយនឹងភាពល្វីងជូរចត់ក្នុងដួងចិត្ត [ របស់គាត់ ] ចំពោះមនុស្ស និងព្រះ នោះគ្មានកន្លែងណាក្នុងចិត្តនឹងទទួលសារនៃដំណឹងល្អនោះទេ ។ [ គាត់ ] ត្រូវការជំនួយខាងសាច់ឈាម ហើយតាមដែលខ្ញុំដឹង គឺគ្មានអង្គការណា នៅក្នុងទីក្រុងស្ទើលឡីន ដែលអាចផ្ដល់ជំនួយនោះដល់ [ គាត់ ] បានទេ » ។[1]

ជាច្រើនទសវត្សរ៍ក្រោយមក ប្រជាជននៅលើពិភពលោកបានរងទុក្ខលំបាក ដោយសារការចុះដុនដាបខាងសេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរ ។ គឺពេលនោះហើយ គឺនៅថ្ងៃទី 6 ខែ មេសា ឆ្នាំ 1936 ដែលប្រធាន ហ៊ីប៊ើរ ចេ ក្រាន្ត និងទីប្រឹក្សារបស់គាត់ ជេ រ៉ូប៊ីន ក្លាក ជុញ្ញ័រ និង ដេវីឌ អូ មិកឃេ បានប្រកាសពីអ្វីដែលក្រោយមកត្រូវបានហៅថាជាកម្មវិធីសុខុមាលភាពនៃសាសនាចក្រ ។ ពីរសប្ដាហ៍ក្រោយមក អែលឌើរ មេលវិន ជី បាឡាដ ត្រូវបានចាត់តាំងជាប្រធានទីមួយនៃកម្មវិធីនោះ និង ហារ៉ូល ប៊ី លី ជានាយកគ្រប់គ្រងទីមួយ ។

នេះពុំមែនជាការខិតខំខ្នះខ្នែងធម្មតានោះទេ ។ ទោះជាព្រះអម្ចាស់បានលើកព្រលឹងដ៏អស្ចារ្យជាច្រើនឡើង ដើម្បីបម្រើក្នុងកម្មវិធីនេះ ក៏ប្រធាន ជេ រ៉ូប៊ីន ក្លាក បានមានប្រសាសន៍យ៉ាងច្បាស់ថា « ការរៀបចំកម្មវិធី [ សុខុមាលភាព ] គឺជាលទ្ធផលមកពីវិវរណៈ តាមរយៈព្រះវិញ្ញាណបរិសុទ្ធ ដល់ប្រធាន ក្រាន្ត ដែលអនុវត្តចាប់តាំងពីគ្រានោះមក ដោយវិវរណៈដូចគ្នាដែលបងប្អូនប្រុស ដែលបានគ្រប់គ្រងកម្មវិធីនេះបានទទួល » ។[2]

ការតាំងចិត្តរបស់អ្នកដឹកនាំសាសនាចក្រ ក្នុងការជួយសម្រាលដល់ទុក្ខលំបាករបស់មនុស្ស គឺម៉ឺងមាត់ និងមិនផ្លាស់ប្ដូរ ។ ប្រធាន ក្រាន្ត ចង់បាន « ប្រព័ន្ធមួយដែលនឹងឈោងជួយ និងថែទាំប្រជាជន មិនថាត្រូវចំណាយច្រើនប៉ុណ្ណានោះទេ » ។ គាត់បានមានប្រសាសន៍ថា សូម្បីតែគាត់នឹងត្រូវ « បិទថ្នាក់សិក្ខាសាលា បញ្ឈប់កិច្ចការផ្សព្វផ្សាយសាសនា មួយរយៈ ឬក៏សូម្បីតែត្រូវបិទព្រះវិហារបរិសុទ្ធ ប៉ុន្តែពួកគេនឹងមិនទុកឲ្យមនុស្សត្រូវអត់ឃ្លាននោះទេ » ។[3]

ខ្ញុំបាននៅក្បែរ ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី នៅទីក្រុង ម៉ាណាហ្គួ ប្រទេស នីការ៉ាហ្គា ពេលដែលគាត់បានមានប្រសាសន៍ទៅកាន់សមាជិកនៃសាសនាចក្រ ដែលរួចជីវិតពីព្យុះសង្ឃរាដ៏ហិនហោច ដែលបានឆក់យកជីវិតមនុស្សជាង 19,000 នាក់ ។ គាត់បានមានប្រសាសន៍ថា « ដរាបណាសាសនាចក្រនៅតែមានធនធាន យើងនឹងមិនទុកឲ្យអ្នកអត់ឃ្លាន ឬគ្មានសំលៀកបំពាក់ ឬគ្មានជម្រកនោះទេ ។ យើងនឹងធ្វើអ្វីៗទាំងអស់ដែលយើងអាចធ្វើបាន ដើម្បីជួយតាមរបៀបដែលព្រះអម្ចាស់បានកំណត់ » ។[4]

លក្ខណៈដ៏ពិសេសមួយនៃកិច្ចការដែលផ្ដោតទៅលើដំណឹងល្អពោរពេញដោយការបំផុសនេះ គឺជាការសង្កត់បញ្ជាក់របស់វាចំពោះការទទួលខុសត្រូវផ្ទាល់ខ្លួន និងការពឹងផ្អែកលើខ្លួនឯង ។ ប្រធាន ម៉ារ៉ុន ជី រ៉មនី បានពន្យល់ថា « កម្មវិធីជាច្រើនត្រូវបានបង្កើតឡើងដោយបុគ្គលទាំងឡាយដែលមានបំណងល្អ

ដើម្បីជួយដល់ពួកអ្នកដែលត្រូវការជំនួយ ។ ទោះជាយ៉ាងណា កម្មវិធីជាច្រើនត្រូវបានរៀបចំឡើងដោយទិសដៅរយៈពេលខ្លី ‹ ក្នុងការជួយមនុស្ស › ដែលផ្ទុយទៅនឹង ‹ ការជួយមនុស្សឲ្យជួយខ្លួនឯង › » ។[5]

ការពឹងផ្អែកលើខ្លួនឯង គឺជាលទ្ធផលនៃការរស់នៅដោយមានការបម្រុងទុក និងការអនុវត្តន៍ការដាក់វិន័យសេដ្ឋកិច្ចផ្ទាល់ខ្លួន ។ តាំងពីដំបូងមក សាសនាចក្របានបង្រៀនក្រុមគ្រួសារ---ចាំបាច់ទទួលខុសត្រូវចំពោះសុខុមាលភាពផ្នែកសាច់ឈាមរបស់ខ្លួនផ្ទាល់ ---ឲ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបាន ។ គ្រប់ជំនាន់តម្រូវឲ្យរៀនដោយខ្លួនឯងនូវមូលដ្ឋានគ្រឹះនៃការពឹងផ្អែកលើខ្លួនឯង ៖ ជៀសវាងពីបំណុល ចាត់ចែងលុយកាក់ដោយប្រុងប្រយ័ត្ន បម្រុងទុកសម្រាប់ពេលមានអាសន្ន ស្ដាប់ និងធ្វើតាមពាក្យសម្ដីព្យាការីដែលនៅរស់ អភិវឌ្ឍវិន័យដើម្បីចែកឲ្យដាច់មួយណាជាសេចក្ដីត្រូវការ និងការចង់បាន ហើយរស់នៅឲ្យបានសមស្របតាមគោលការណ៍ទាំងនោះ ។

គោលបំណង ការសន្យា និងគោលការណ៍ដែលពង្រឹងកិច្ចការរបស់យើងក្នុងការមើលថែដល់ជនទីទ័លក្រ និងជនទុរគតបានពង្រីកហួសពីជីវិតរមែងស្លាប់នេះ ។ កិច្ចការដ៏ពិសិដ្ឋនេះ មិនត្រឹមតែផ្ដល់ប្រយោជន៍ និងពរជ័យដល់ពួកអ្នកដែលរងទុក្ខ ឬដែលត្រូវការជំនួយនោះទេ ។ ដោយជាបុត្រាបុត្រីនៃព្រះ យើងមិនអាចទទួលមរតកនៃភាពពោរពេញនៃជីវិតសេឡេស្ទាល ដោយគ្មានការខ្វល់ខ្វាយទាំងស្រុង ចំពោះគ្នាទៅវិញទៅមក ពេលយើងនៅលើផែនដីនេះទេ ។ វាគឺនៅក្នុងការអនុវត្តន៍នៃសេចក្ដីសប្បុរសនៃការលះបង់ និងប្រគល់ខ្លួនម្នាក់ដល់អ្នកដទៃដែលយើងអាចរៀនពីគោលការណ៍សេឡេស្ទាលនៃការលះបង់ និងការថ្វាយ ។[6]

ស្ដេច បេនយ៉ាមីន ដ៏អស្ចារ្យ បានបង្រៀនថា មូលហេតុមួយដែលយើងចែករំលែកទ្រព្យរបស់យើងដល់អ្នកទ័លក្រ ហើយជួយគាំទ្រពួកគេ គឺដើម្បីឲ្យយើងអាចមានការផ្ដាច់បាបទាំងឡាយរបស់យើង ពីមួយថ្ងៃទៅមួយថ្ងៃ ហើយដើរដោយឥតទោសចំពោះព្រះ ។[7]

តាំងពីការបង្កើតផែនដីមក ក្រណាត់នៃសង្គមដ៏សុចរិតតែងត្រូវបានត្បាញមកពីសរសៃមាសនៃសេចក្ដីសប្បុរស ។ យើងចង់បានពិភពលោកដ៏សុខសាន្តមួយ និងសហគមន៍ដែលចម្រើនឡើង ។ យើងអធិស្ឋានសូមឲ្យមាននូវសង្គមដ៏ល្អ និងមានគុណធម៌ដែលភាពទុច្ចរិតត្រូវបោះបង់ចោល ហើយសេចក្ដីល្អ និងត្រឹមត្រូវមានជ័យជំនះ ។ មិនថាយើងកសាងព្រះវិហារបរិសុទ្ធច្រើនយ៉ាងណា មិនថាសមាជិកភាពរបស់យើងលូតលាស់យ៉ាងណា មិនថាលោកិយគិតពីយើងក្នុងផ្លូវវិជ្ជមានយ៉ាងណានោះទេ ---តើយើងគួរតែបរាជ័យក្នុងការកាន់តាមបទបញ្ញត្តិដ៏សំខាន់អស្ចារ្យនេះទេ ដែលថា « ចូរជួយអ្នកទន់ខ្សោយ ចូរលើកដៃដែលពោយ ហើយចូរចម្រើនកម្លាំងដល់ក្បាលជង្គង់ដែលញ័រ »[8] ឬបែរចេញពីពួកអ្នកដែលមានទុក្ខ និងទូញយំ នោះយើងនៅក្រោមការកាត់ទោសហើយ ហើយមិនអាចសព្វព្រះហឫទ័យព្រះអម្ចាស់ឡើយ[9] ហើយក្ដីសង្ឃឹមដ៏រីករាយនៃដួងចិត្តយើងនឹងមិននៅជិតយើងទេ ។

នៅទូទាំងពិភពលោក ប៊ីស្សព 27,000 នាក់ ស្វែងរកអ្នកទ័លក្រ ដើម្បីផ្គត់ផ្គង់ដល់សេចក្ដីត្រូវការរបស់គេ ។ ប៊ីស្សពម្នាក់ៗបានជំនួយពីក្រុមប្រឹក្សាវួដដែលរួមមាន អ្នកដឹកនាំបព្វជិតភាព និងអង្គការជំនួយផ្សេងៗ រួមទាំងប្រធានសមាគមសង្គ្រោះដែលពោរពេញដោយការលះបង់ ។ ពួកគេអាចផ្ដល់ការសង្គ្រោះបានយ៉ាងលឿនដល់អ្នកដែលគេមិនស្គាល់ ...ចាក់ប្រេង និងស្រា លាបដល់ដួងចិត្តដែលឈឺចាប់ ...[ ហើយ ] ជូតទឹកភ្នែកដល់ក្មេងកំព្រា និងធ្វើឲ្យដួងចិត្តស្ត្រីមេម៉ាយបានរីករាយ » ។[10]

ដួងចិត្តរបស់សមាជិក និងអ្នកដឹកនាំសាសនាចក្រនៅទូទាំងពិភពលោក កំពុងទទួលឥទ្ធិពលវិជ្ជមាន និងកំពុងត្រូវបានដឹកនាំដោយគោលលទ្ធិទាំងឡាយ និងដោយវិញ្ញាណដ៏ទេវភាពនៃការស្រឡាញ់ និងការខ្វល់ខ្វាយចំពោះអ្នកជិតខាងរបស់គេ ។ អ្នកដឹកនាំបព្វជិតភាព នៅអាមេរិកខាងត្បូង មានភារៈចំពោះភាពអត់ឃ្លាន និងភាពខ្វះខាតនៃសមាជិកក្នុងស្តេកដ៏តូចរបស់គាត់ ។

ដោយមិនអនុញ្ញាតឲ្យកូនៗត្រូវរងទុក្ខដោយការអត់ឃ្លាន នោះគាត់បានរកដីទំនេរមួយកន្លែង ហើយបានរៀបចំអ្នកកាន់បព្វជិតភាពឲ្យភ្ជួររាស់ និងដាំដុះលើដីនោះ ។ ពួកគេបានរកសេះចាស់បានមួយក្បាល ហើយបានថ្ពក់ភ្ជាប់នឹងនង្គ័លដ៏សាមញ្ញមួយ ហើយចាប់ផ្ដើមធ្វើការនៅលើដីនោះ ។ ប៉ុន្តែ មុនពេលដែលគេអាចបញ្ចប់ការងារនោះបាន សោកនាដកម្មបានកើតឡើង ហើយសេះចំណាស់ក៏បានងាប់ទៅ ។

ជាជាងទុកឲ្យបងប្អូនប្រុសស្រីរបស់គេត្រូវរងទុក្ខដោយការអត់ឃ្លាន បងប្អូនប្រុសអ្នកកាន់បព្វជិតភាពទាំងនោះបានចងភ្ជាប់នង្គ័លដ៏ចាស់នោះទៅនឹងស្មារបស់ពួកគាត់ ហើយទាញវាឆ្លងដីដ៏រឹងនោះ ។ ពួកគាត់បានដាក់មកលើខ្លួនពួកគាត់នូវនឹមនៃសេចក្ដីទុក្ខវេទនា និងបន្ទុករបស់បងប្អូនប្រុសស្រីរបស់ពួកគាត់ ។[11]

ព្រឹត្តិការណ៍មួយពីប្រវត្តិក្រុមគ្រួសាររបស់ខ្ញុំ ជាឧទាហរណ៍នៃការតាំងចិត្តដើម្បីថែទាំពួកអ្នកដែលត្រូវការជំនួយ ។ អ្នករាល់គ្នាជាច្រើន បានឮពីក្រុមរទេះរបស់វិល្លី និង ម៉ាទីន និងពីរបៀបដែលអ្នកត្រួសត្រាយផ្លូវដ៏ស្មោះត្រង់ទាំងនោះ បានរងទុក្ខវេទនា និងបានស្លាប់ ពេលដែលពួកគាត់បានតស៊ូនឹងភាពត្រជាក់នៃរដូវរងា និងស្ថានភាពដ៏ល្វិតល្វៃ ក្នុងដំណើរឆ្ពោះទៅទិសខាងលិចរបស់ពួកគាត់ ។ រ៉ូប៊ឺត ថៃឡ័រ ប៊ឺតុន គឺជាលោកតាលួតម្នាក់របស់ខ្ញុំ ជាម្នាក់ក្នុងចំណោមអ្នកដែលលោកព្រិកហាំ យ៉ង់ បានសុំឲ្យទៅ ហើយសង្គ្រោះពួកបរិសុទ្ធជាទីស្រឡាញ់ និងអស់សង្ឃឹមទាំងនោះ ។

ពីគ្រានោះ លោកតាបានសរសេរក្នុងកំណត់ហេតុរបស់គាត់ថា « ព្រិលក្រាស់ ហើយត្រជាក់ខ្លាំងណាស់ ...ត្រជាក់ខ្លាំងណាស់រហូតដល់ [ យើង ] មិនអាចកម្រើកបាន ។ ប្រដាប់ស្ទង់កម្ដៅ 24 ដឺក្រេក្រោមសូន្យ ... ត្រជាក់ខ្លាំងណាស់ ប្រជាជនមិនអាចធ្វើដំណើរបានទេ » ។
សម្ភារសង្គ្រោះជីវិតត្រូវបានចែកចាយទៅពួកបរិសុទ្ធដែលនៅដាច់ពីគេនោះ ប៉ុន្តែ « ថ្វីបើ [ ពួកគាត់ ] ទាំងអស់គ្នាអាចធ្វើបាន ក៏មនុស្សជាច្រើនទៀតបានស្លាប់ និងត្រូវបានកប់នៅតាមផ្លូវ » ។

កាលដែលពួកបរិសុទ្ធដែលត្រូវបានសង្គ្រោះនោះ កំពុងតែឆ្លងកាត់ការលំបាកមួយតាមជ្រោះអេកូ នោះមានរទេះមួយចំនួនបានឈប់សិន ដើម្បីជួយដល់ការប្រសូតរបស់ទារិកាម្នាក់ ។ រ៉ូប៊ឺត បានកត់សម្គាល់ថា ម្ដាយវ័យក្មេងមិនមានក្រណាត់គ្រប់គ្រាន់ដើម្បីគ្របដណ្ដប់ឲ្យទារកទើបនឹងកើតរបស់នាងបានកក់ក្ដៅនោះទេ ។ ដូច្នេះ ទោះជាសីតុណ្ហភាពត្រជាក់យ៉ាងណា ក៏គាត់ « បានដោះអាវរបស់គាត់ ហើយឲ្យទៅម្ដាយដើម្បីរុំទារកតូច » ។ ទារកនោះត្រូវបានគេដាក់ឈ្មោះថា អេកូ—អេកូ—ដើម្បីរំឭកចាំពីកន្លែង និងស្ថានភាពនៃកំណើតរបស់នាង ។

ប៉ុន្មានឆ្នាំក្រោយមក រ៉ូប៊ឺត ត្រូវបានហៅជាគណៈប៊ីស្សពជាអធិបតីនៃសាសនាចក្រ ដែលគាត់បានបម្រើអស់ជាងបីទសវត្សរ៍ ។ នៅអាយុ 86 ឆ្នាំ រ៉ូប៊ឺត ថៃឡ័រ ប៊ឺតុន បានធ្លាក់ខ្លួនឈឺ ។ គាត់បានប្រមូលក្រុមគ្រួសាររបស់គាត់នៅឯក្បែរគ្រែរបស់គាត់ ដើម្បីផ្ដល់ពរជ័យចុងក្រោយរបស់គាត់ ។ ក្នុងពាក្យពេចន៍ចុងក្រោយរបស់គាត់ គឺសាមញ្ញ ប៉ុន្តែជាដំបូន្មានដ៏ជ្រាលជ្រៅ ៖ « ចូរមានចិត្តសន្ដោសចំពោះអ្នកទ័លក្រ » ។

បងប្អូនប្រុសស្រី យើងគោរពចំពោះបុគ្គលដែលពោរពេញដោយគំនិតទាំងនោះ ដែលព្រះអម្ចាស់បានហៅដើម្បីស្ថាបនា និងគ្រប់គ្រងកម្មវិធីនៃការពង្រីកការបម្រើនោះ ដល់សមាជិកដែលក្រខ្សត់ក្នុងសាសនាចក្ររបស់ទ្រង់ ។ យើងគោរពដល់ពួកអ្នក ដែលសព្វថ្ងៃនេះ ឈោងជួយក្នុងរបៀបរាប់មិនអស់ និងដោយស្ងប់ស្ងាត់ ដើម្បី « មានចិត្តសន្ដោសចំពោះអ្នកទ័លក្រ » ចិញ្ចឹមពួកអ្នកដែលអត់ឃ្លាន បំពាក់ពួកអ្នកអាក្រាត ជួយសង្គ្រោះដល់ពួកអ្នកឈឺ និងសួរសុខទុក្ខអ្នកជាប់ឃុំឃាំង ។

នេះជាកិច្ចការដ៏ពិសិដ្ឋ ដែលព្រះអង្គសង្គ្រោះរំពឹងពីពួកសិស្សរបស់ទ្រង់ ។ វាជាកិច្ចការដែលទ្រង់បានស្រឡាញ់ នៅពេលទ្រង់បានមានព្រះជន្មលើផែនដី ។ វាជាកិច្ចការដែលខ្ញុំដឹងថា យើងនឹងឃើញទ្រង់ធ្វើ បើសិនជាទ្រង់នៅក្នុងចំណោមយើងសព្វថ្ងៃនេះ ។[12]

75 ឆ្នាំ កន្លងមកហើយ ប្រព័ន្ធមួយដែលបានឧទ្ទិសដល់សេចក្ដីសង្គ្រោះខាងវិញ្ញាណ និងខាងសាច់ឈាមនៃមនុស្សលោក បានរីកចម្រើនឡើង ពីការចាប់ផ្ដើមដ៏រាបទាប ។ តាំងពីពេលនោះមក វាបានលើកតម្កើង និងផ្ដល់ពរជ័យដល់ជីវិតជាច្រើនលាននាក់ទូទាំងពិភពលោក ។ ផែនការសុខុមាលភាពដែលបានពីការព្យាករណ៍នេះ មិនមែនគ្រាន់តែជារឿងមួយដែលមិនសូវសំខាន់នៅក្នុងប្រវត្តិសាសនាចក្រនោះទេ ។ គោលការណ៍ទាំងឡាយដែលវាផ្អែកលើកំណត់ថាយើងជាមនុស្សបែបណា ។ វាជាគោលនៃចរិតលក្ខណៈរបស់យើងក្នុងនាមជាសិស្សនៃព្រះអង្គសង្គ្រោះ និងជាគំរូរបស់យើង គឺព្រះយេស៊ូវ ជាព្រះគ្រីស្ទ ។

កិច្ចការនៃការខ្វល់ខ្វាយចំពោះគ្នាទៅវិញទៅមក និងមាន « ចិត្តសន្ដោសចំពោះអ្នកទ័លក្រ » គឺជាកិច្ចការដ៏បរិសុទ្ធ ដែលបានបញ្ជាដោយព្រះវរបិតា ហើយត្រូវបានរៀបចំឡើងយ៉ាងពិសិដ្ឋ ដើម្បីផ្ដល់ពរជ័យ ដុសខាត់ និងលើកតម្កើងកូនៗរបស់ទ្រង់ ។ សូមឲ្យយើងដើរតាមដំបូន្មានរបស់ព្រះអង្គសង្គ្រោះទៅកាន់

អ្នកប្រាជ្ញច្បាប់ម្នាក់នោះ ក្នុងការប្រៀបធៀបទៅនឹងសាសន៍សាម៉ារីដ៏ល្អ « ទៅចុះ ចូរអ្នកប្រព្រឹត្តបែបយ៉ាងដូច្នោះដែរ » ។[13] ខ្ញុំថ្លែងទីបន្ទាល់ទាំងនេះក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. Clare Middlemiss, *Cherished Experiences from the Writings of President David O. McKay* ទំព័រ 189 ។

2. « Testimony of Divine Origin of Welfare Plan » *Church News* ថ្ងៃទី 8 ខែ សីហា ឆ្នាំ 1951 ទំព័រ 15 ដូចដែលបានដកស្រង់ក្នុង Glen L. Rudd, *Pure Religion* ទំព័រ 46, 47 ។

3. Glen L. Rudd, *Pure Religion* ទំព័រ 34 ។

4. *LDS Church News* ថ្ងៃទី 28 ខែ វិច្ឆិកា ឆ្នាំ 1998 ។

5. Marion G. Romney, *Ensign* ខែ វិច្ឆិកា ឆ្នាំ 1982ទំព័រ91 ។

6. សូមមើល គោលលទ្ធិ និងសេចក្ដីសញ្ញា 104:15–18; សូមមើលផងដែរ គោលលទ្ធិ និងសេចក្ដីសញ្ញា 105:2–3 ។

7. សូមមើល ម៉ូសាយ 4:26, 27 ។

8. គោលលទ្ធិ និងសេចក្ដីសញ្ញា 81:5 សូមមើល ម៉ាថាយ 22:36–40 ។

9. សូមមើល គោលលទ្ធិ និងសេចក្ដីសញ្ញា 104:18 ។

10. *History of the Church*, 4:567–68; ដកស្រង់ចេញពី « Ladies′ Relief Society » បានបោះពុម្ពនៅក្នុង *Times and Seasons* ថ្ងៃទី 1 ខែ មេសា ឆ្នាំ 1842 ទំព័រ 743 យ៉ូសែប ស្ម៊ីធ គឺជាអ្នកនិពន្ធនៅពេលនោះ ។

11. បទសម្ភាសន៍ជាមួយ Harold C. Brown, អតីតនាយកគ្រប់គ្រងនៃសេវាកម្មសុខុមាលភាព ។

12. សូមមើល Dieter F. Uchtdorf « You Are My Hands » *លីអាហូណា* និង *Ensign* ខែ ឧសភា ឆ្នាំ 2010 ។

13. លូកា 10:37 ។